# គ្រូនិងសិស្ស - រឿងនិទានឡាវ



នេះជារឿងនិទានឡាវ ស្ដីពីលោកសង្ឃចាស់មួយអង្គ មានសិស្សម្នាក់ឈ្មោះកែវ។ ព្រឹកមួយ លោកគ្រូបាន ហៅសិស្សមកប្រាប់ «អឺ អាកែវ! ព្រឹកនេះ ឯងមិនបាច់ ទៅតាមអញដើរបិណ្ឌបាតទេ! ឯងនៅបោសច្រាសទាំង ក្នុងទាំងក្រៅកុដិឱ្យស្អាត! អាឯងនេះចំជាកម្ជិលផេះ ចាំ ឱ្យតែអញត្អូញដូចចន្ទុះ ... មើលចុះ សុទ្ធតែអាចម៍មាន់ឱ្យ ពាស! បោសច្រាសឱ្យស្អាតវ៉ើយ តែអញមកវិញ ឃើញ មានអាចម៍មាន់ អញឱ្យឯងស៊ីហើយវ៉ី!...» ផ្ដាំហើយលោកគ្រូក៏និមន្តចេញទៅបិណ្ឌបាតទៅ។ លុះលោកគ្រូត្រលប់មកពីបិណ្ឌបាតវិញ ឃើញសុទ្ធតែអាចម៍មាន់ស្អេកស្កះលើសពីព្រឹកទៅទៀត លោក ខ្ញាល់ខ្លាំងណាស់ ក៏ស្រែកហៅ «អាកែវ! អញឱ្យឯងបោសថ្នាកុដិឱ្យស្អាត ម្ដេចអាចោលម្សៀតឯងមិនធ្វើ?» អាកែវរត់ចេញពីក្នុងកុដិមកទទួលលោកគ្រូ «ខ្ញុំព្រះករុណាបោសហើយតើ លោកគ្រូ!» លោកគ្រូស្រែកសម្លុត «អាឯងស្មានថាអញខ្វាក់ឬ អាកែវ? មើល សុទ្ធតែអាចម៍មាន់ឱ្យពាស!» អាកែវស្រែកបែបភ្ញាក់ «ពុទ្ធោ! ច្បាស់ជាអាពួកមាន់ចង្រៃអស់នោះវាលបចូលមកជុះពេលខ្ញុំព្រះករុណាជូត សម្អាតខាងក្នុងកុដិហើយ លោកគ្រូ!»

«មិនបាច់ដោះសាទេ អាកែវ! អញប្រាប់ហើយ ថាបើអញមកវិញ ឃើញអាចម៍មាន់ អញឱ្យឯងស៊ី! ឥឡូវ អាឯងឆាប់ទៅស៊ីឱ្យទាល់តែស្អាតថ្នាកុដិភ្លាម!»

អាកែវធ្វើមុខជូរ វាដាក់ខ្លួនទៅលើដី ហើយលូកដៃទៅរើសអាចម៍មាន់មួយដុំមកដាក់មាត់ផ្ទប់ រួចវាស្រែកថា «យី អាចម៍មាន់ផ្អែមឆ្ងាញ់ណាស់តើ យូរហើយកុំឱ្យតែដឹង!...» វាវារទៅរើសដុំអាចម៍មាន់ផ្សេងទៀត យកមក ទំពាស៊ីយ៉ាងរួសរាន់រីករាយ។

ឃើញសិស្សស៊ីអាចម៍មាន់ទំនងជាឆ្ងាញ់ លោកគ្រូឆ្ងល់ណាស់ក៏សួរ «អាចម៍មាន់ឆ្ងាញ់មែនឬ អាកែវ?» អាកែវជក់ស៊ីស្ទើរមិនចង់ងើបមុខឆ្លើយ «ព្រះករុណា ឆ្ងាញ់ខ្លាំងណាស់!...»

លោកគ្រូទ្រាំមិនបាន ក៏ឱនទៅរើសអាចម៍មាន់មួយដុំមកលិទ្ធសាកមើល ឃើញថាផ្អែមឆ្ងាញ់ពិតមែន ក៏ ប្រញាប់ស្រែកឃាត់សិស្សឱ្យឈប់ស៊ី ដើម្បីទុកឱ្យលោកឆាន់តែម្នាក់ឯង។ លុះឆាន់អាចម៍មាន់អស់ហើយ លោកគ្រូក៏ប្រាប់ថាសិស្សថា «ចាប់ពីថ្ងៃនេះទៅ ចូរអាកែវឯងឈប់បោសអាចម៍មាន់ចោលទៀត ត្រូវទុក ឱ្យអាត្មាអញឆាន់!»

ស្អែកឡើង ពេលវិលត្រលប់មកពីបិណ្ឌបាតវិញ លោកគ្រូក៏ប្រញាប់ប្រញាល់ចូលទៅរើសអាចម៍មាន់ដែល នៅរាយប៉ាយលើថ្នាកុដិ មកឆាន់ ស្រាប់តែធ្វើមុខជូរហើយស្រែកថា «ម្ដេចអាចម៍មាន់ថ្ងៃនេះ មិនឆ្ងាញ់មិន ឈ្ងុយដូចកាលពីម្សិលមិញ?» លោកគ្រូឆាន់សាកអស់ពីរ-បីដុំទៀត ទើបដឹងថាចាញ់បោកអាកែវស្មោះ!... អាកែវជាក្មេងធ្លាប់រប៉ិលរប៉ូចខិលខូចតែបែបនេះឯង គឺកាលពីម្សិលមិញ ក្រោយដែលវាបានបោសសម្អាតទី ថ្នាកុដិយ៉ាងស្អាតរៀបរយហើយ វាទៅយកស្ករត្នោតកូរលាយនិងខ្ទិះដូងរហូតដល់ខាប់ រួចវាយកទៅបន្តក់ រាយលើថ្នាកុដិ ធ្វើរាងដូចអាចម៍មាន់ ត្រង់នេះមួយដុំ ត្រង់នោះមួយដុំ ... អញ្ចឹងទើបបានជាលោកគ្រូឆាន់ទៅ មានរសជាតិឆ្ងាញ់ពិសា ... មិនដូចថ្ងៃនេះឯណា លោកគ្រូឆាន់អាចម៍មាន់មែនទែន!

រឿងព្រេងខ្មែរយើងក៏មាននិទានអំពីគ្រូកាច-សិស្សខូចប្រហាក់ប្រហែលរឿងឡាវខាងលើហ្នឹងដែរ។

ប្រែសម្រួលដោយៈ ប៊ុនចាន់ សុក្រសិរី